STREAM ឆ្នាំទី៣ លេខ៣ ខែ កក្កដា-កញ្ញា ២០០៤

Support to Regional Aquatic Resources Management
គំរោងជួយគ្រប់គ្រងធនធានវារីជាតិក្នុងតំបន់

# ទស្សនាវដ្តី STREAM

## ការទំនាក់ទំនង និង ការរៀនសូត្រពីជីវភាពរស់នៅរបស់អ្នកនេសាទ និង កសិករ

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

# មាតិកា


| អត្ថបទ | ទំព័រ |
| --- | --- |
| តើយើងត្រូវការអ្វីខ្លះដើម្បី ស្វែងយល់អំពីការរស់នៅរបស់ប្រជាកសិករ ? | ១ |
| ដោយ *Kath Copley and William Savage* | |
| ការជ្រើសរើសជំហានដើម្បីឱ្យប្រពន្ធ័ការចិញ្ចឹមជីវិតមានដំណើរការ | ៤ |
| ដោយ *Erwin L Pador* | |
| ការឆ្លុះបញ្ចាំងនៃសិក្ខាសាលានៅ India-Nepal | ៧ |
| ដោយ *Rubu Mukherjee and Nilkanth Pokhrel* | |
| ការឆ្លុះបញ្ចាំងពីតួនាទី នៃការធ្វើវិភាគ និងការអនុវត្តន៍ប្រពន្ធ័របរចិញ្ចឹមជីវិតនៅប្រទេសឡាវ | ៩ |
| ដោយ *Phanthavong Vongsamphanh and Graham Haylor* | |
| បន្ទាប់ពីសិក្ខាសាលាស្តីពី ប្រពន្ធ័ការចិញ្ចឹមជីវិត និងការវិភាគ | ១២ |
| ដោយ *Khin Maung Soe, Aye Aye Zaw, Nilar Kyawe and Myant Thar Htun* | |
| ការទំនាក់ទំនង និងសារៈសំខាន់នៃប្រពន្ធ័ចិញ្ចឹមជីវិតនៅ យូណាន, ប្រទេសចិន | ១៥ |
| ដោយ *Susan Li and William Savage* | |
| ពត៌មានពីទស្សនាវដ្តី **STREAM** | ១៧ |
| ពត៌មានពី **STREAM** | ១៩ |

## **កំណត់ចំណាំ:**

ទស្សនាវដ្ដី លេខនេះបានប្រមូលអត្ថបទពិសេស៧ពីសិក្ខាសាលាស្ដីពី ការវិភាគរបរចិញ្ចឹមជីវិត ដែលរៀបចំឡើងដោយ គំរោង FAO មានឈ្មោះថា គំរោងកាត់បន្ថយភាពក្រីក្រតាមរយៈការកែលំអការគ្រប់គ្រងធនធានវារីជាតនៅតំបន់អាស៊ីប៉ាស៊ីភិច ។ សិក្ខាសាលាទាំងនេះបានប្រារព្ធឡើងនៅប្រទេសហ្វីលីពីន (ខែវិច្ឆិកា ២០០៣), ប្រទេសឥណ្ឌា និងនេប៉ាល (ខែកុម្ភៈ ២០០៤), ឡាវ (ខែមិនា ២០០៤), ភូមា (ខែឧសភា ២០០៤) និងនៅយូណាន ប្រទេសចិន (ខែកញ្ញា ២០០៤) ។

អ្នកនិពន្ធអត្ថបទនេះ នឹងផ្ដោតលើបទពិសោធន៍ដែលពួកបានជួបប្រទះដែលជាលទ្ធផលនៃអង្គសិក្ខាសាលា, ឬជាសមិទ្ធផលដែលគួរឱ្យកត់សំគាល់ដែលពួកគេបានដឹង ។ ការប្រមូលអត្ថបទឡើងវិញនឹងត្រូវបានបោះពុម្ពផ្សាយដោយរួមបញ្ចូល ទាំងសិក្ខាសាលាជាលើកចុងក្រោយដែលនឹងត្រូវធ្វើឡើងនៅ ឡូស្បាញូស ប្រទេសហ្វីលីពីនក្នុងខែ មិនា ឆ្នាំ ២០០៥ ខាងមុខនេះ ដែលគាំទ្រដោយ FAO-TCP សិក្ខាសាលានេះមានឈ្មោះថា "សិក្ខាសាលា FAO/NACA-STREAMស្ដីពី ធនធានវារីជាតិ និងការចិញ្ចឹមជីវិតៈ ទំនាក់ទំនងគោលនយោបាយ និងប្រជាជន " (Aquatic Resources and Livelihoods: Connecting Policy and People) ។ គោលបំណងសំខាន់នៃសិក្ខាសាលាគឺ ពិនិត្យឡើងវិញ និងចែករំលែកបទពិសោធន៍របស់គំរោង STREAM ដែលស្ថិតនៅក្រោម FAO-TCP និងបង្កើតឱ្យមានការយល់ស្របគ្នាអំពីតំលៃនៃរបរចិញ្ចឹមជីវិតជាមួយការគ្រប់គ្រងធនធានវារីជាត និងការកាត់បន្ថយភាពក្រីក្រ ។ អ្នកដែលចូលរួមមានៈ តំណាងសមាជិករដ្ឋាភិបាលនៃក្រុមប្រឹក្សា NACA, អ្នកសំរបសំរួលថ្នាក់ជាតិនៃគំរោង STREAM, ប្រធានទំនាក់ទំនង STREAM និងសមាជិក FAO-TCP ។

យើងមានក្ដីសោមនស្សយ៉ាងខ្លាំងចំពោះ FAO ដោយបានផ្ដល់ជាថវិកាក្នុងការរៀបចំសិក្ខាសលាដ៏មានសារៈសំខាន់ស្ដីពីរបរចិញ្ចឹមជីវិតរបស់ប្រជាកសិករ ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Rohana Subasinghe, FAO Senior Fishery Officer និងលោក Simon Funge-Smith, FAO Aquaculture Officer ដែលបានសហការ និងជួយគំរោង STREAM រហូតសំរេចបាសមិទ្ធិផលជាផ្លែផ្កា ។

សូមលោកអ្នកអានដោយក្ដីរីករាយ

លោក Graham Haylor នាយកគំរោង STREAM

លោក William Savage បណ្ណាធិការទស្សនាវដ្ដី STREAM

# តើយើងត្រូវការអ្វីខ្លះដើម្បីស្វែងយល់អំពីរបៀបនៃការរស់នៅរបស់ប្រជាកសិករ ?

*Kath Copley* និង *William Savage*

## សំណួរ និងសិក្ខាសាលា

សិក្ខាសាលាចំនួន ៥ របស់ NACA-STREAM/FAO ស្តីពី ការវិភាគ និងរបរចិញ្ចឹមជីវិតរបស់ប្រជាកសិករ គឺជាសកម្មភាពរបស់ FAO ដែលផ្តល់ថវិកា ដោយកម្មវិធី TCP មានឈ្មោះថា "កម្មវិធីកាត់បន្ថយភាពក្រីក្រតាមរយៈការកែលំអ ការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់អាស៊ីប៉ាស៊ីភិច "។ សិក្ខាសាលាបានប្រារព្ធឡើងចាប់ពី វិច្ឆិកា ឆ្នាំ ២០០៣ រហូតដល់ខែកញ្ញាឆ្នាំ ២០០៤ នៅប្រទេស ហ្វីលីពីន, ឥណ្ឌានិងនេប៉ាល់, ឡាវ, ភូមា និងយូណាន ប្រទេសចិន ។

ទិសដៅសំខាន់នៃអង្គសិក្ខាសាលាគឺ ដើម្បីបង្កើត និងចងក្រងឯកសារសំរាប់បណ្តុះបណ្តាលពីរបរចិញ្ចឹមជីវិត និងការវិភាគ , និងពង្រឹងសមត្ថភាពតាមបណ្តាប្រទេសនីមួយៗដើម្បីធ្វើការវិភាគរបរចិញ្ចឹមជីវិត ។ គោលបំណងសិក្ខាសាលាគឺ:

- យល់ដឹងពីបញ្ហានៃការចាប់អារម្មណ៏ចំពោះប្រជាជនដែលរបរចិញ្ចឹមជីវិតរបស់ពួកគេផ្អែកលើធនធាន វារីជាតិ ជាពិសេស ចំពោះអ្នកដែលមានធនធានតិចតួច ។
- បង្កើតក្រុម របរចិញ្ចឹមជីវិត "livelihoods teams" ដើម្បីធ្វើការបណ្តុះបណ្តាល និងវិភាគរបរចិញ្ចឹមជីវិត និងចែករំលែកបទពិសោធន៏របស់ពួកគេដល់សហគមន៏ និងអ្នកពាក់ពន្ធ័ដ៏ទៃទៀត ។
- ចែករំលែកចំណេះដឹងអំពី ការវិភាគ របរចិញ្ចឹមជីវិតដោយដោយមានការចូលរួម ។
- ពិនិត្យឡើងវិញនូវរាល់ឯកសារដែលមានស្រាប់ស្តីពី ការវិភាគរបរចិញ្ចឹមជីវិត ។
- ជាបទពិសោធន៏ដើម្បីប្រើប្រាស់ឧបករណ៏ដោយមានការចូលរួមលើការវិភាគរបរចិញ្ចឹមជីវិត ។
- បង្កើតផែនការសកម្មភាពសំរាប់អនុវត្តការវិភាគរបរចិញ្ចឹមជីវិត ។

ការរៀបចំសិក្ខាសាលារួមមានការប្រជុំអំពី:

- បទពិសោធន៏ និងការសង្ឃឹមទុក
- ចែករំលែកការយល់ដឹង
- ការបង្កើតជាក្រុម និងអ្នកពាក់ពន្ធ័
- សិក្សាស្វែងយល់អំពី ប្រពន្ធ័ចិញ្ចឹមជីវិត- ក្របខណ្ឌ័នៃការចិញ្ចឹមជីវិត និងដំណោះស្រាយ
- វិភាគការចិញ្ចឹមជីវិត- ដំណើរការ និងការអនុវត្ត
- រៀបចំទស្សនៈកិច្ចនៅតាមសហគមន៏ - តួនាទី និងឧបករណ៏សំរាប់ ទំនាក់ទំនង និងសិក្សាអំពីប្រពន្ធ័ចិញ្ចឹមជីវិត
- របាយការណ៏ទស្សនៈកិច្ចសិក្សា
- ភាសា, ថាមពល និងការទំនាក់ទំនង

☞ផែនការសកម្មភាពសំរាប់ធ្វើការវិភាគប្រពន្ធ័របរចិញ្ចឹមជីវិត

សិក្ខាសាលាបានចំណាយពេលយ៉ាងច្រើនដើម្បីបង្ហាញអំពីភាពសាំញ៉ាំរបស់សហគមន៍ និងក្រុមកសិករ ដោយបានចែករំលែកនូវ ការយល់ដឹង អំពីរបៀបនៃការសិក្សារបរចិញ្ចឹមជីវិតរបស់ពួកគេ ។ សំណួរសំខាន់ក្នុងសិក្ខាសាលាគឺ "តើយើងត្រូវការអ្វីខ្លះដើម្បី ស្វែងយល់អំពីការរស់នៅរបស់ប្រជាកសិករ ?'' ដោយមិនបានគិតពីបទពិសោធន៍ពីមុនៗកន្លងមក លើការវិភាគរបរចិញ្ចឹមជីវិត , អ្នកចូលរួមទាំងឡាយ បានលើកជាសំណួរនេះឡើងក្នុងគោលបំណងស្វែងរកវិធីសាស្ត្រថ្មីៗ ដើម្បីធ្វើការជាមួយសហគមន៍ ។ លើសពីនេះអ្នកចូលរួមមានបំណង ធ្វើដំណើរទៅកាន់សហគមន៍ និងប្រើប្រាស់នូវអ្វីដែលពួកគេបានរៀនសូត្រ ដើម្បីកែលំអវិធីសាស្ត្រដែលពួកគេបានធ្វើការជាមួយសហគមន៍ ។

## ការសង្ឃឹមទុក និងសំភារះ

ការសង្ឃឹមទុករបស់អ្នកដែលបានមកចូលរួមសិក្ខាសាលារួមមានដូចជា: ដើម្បីសិក្សារៀនសូត្រអំពីប្រពន្ធ័របរចិញ្ចឹមជីវិត និងវិធីសាស្ត្រនៃការធ្វើវិភាគ ហើយទទួលបាននូវវប្បធមិតែមួយ និងមានសេចក្តីទុកចិត្ត,គឺមិនត្រឹមតែប្រភពមច្ឆជាតិប៉ុណ្ណោះទេ ។ ដើម្បីមើលឱ្យឃើញនូវបណ្តាញការងារដែលបង្កើតឡើងអាចជួយពួកគេទំនាក់ទំនង ពង្រីកការយល់ដឹងអំពីប្រពន្ធ័របរចិញ្ចឹមជីវិត និងដើម្បីឱ្យមានការទំនាក់ទំនងកាន់តែប្រសើរអំពីបញ្ហាដែលជាប់ពាកាពន្ធ័ជាមួយពួកគេ ( អ្នកចូលរួម) ។

ស្ទើតែគ្រប់កន្លែងដែលសិក្ខាសាលាប្រារព្វឡើង គោលគំនិតនៃរបរចិញ្ចឹមជីវិត និងបច្ចេកទេសសុទ្ធតែថ្មីចំពោះគ្រប់អ្នកចូលរួមទាំងអស់ ។ ដូច្នេះឯកសារជាគន្លឹះដែល STREAM ប្រមូលបានពីក្នុងតំបន់ត្រូវបានបកប្រែ និងប្រើប្រាស់ដោយអ្នកចូលរួម ដើម្បីស្វែងយល់អំពីគោលគំនិតទាំងនោះ: របាយការណ៍ចំនួនពីរស្តីពី គោលការណ៍របរចិញ្ចឹមជីវិត ដែលបានមកពីសិក្ខាសាលានៅប្រទេសកម្ពុជា និងវៀតណាម, ករណីប្រទេសកម្ពុជាមានសៀវភៅស្តីពី ឧបករណ៍វាយតំលៃជនបទដោយមានករចូលរួម (PRA) និងទស្សនាវដ្តី STREAM មួយចំនួនទៀតមានបរិយាយអំពីការវិភាគរបរចិញ្ចឹមជីវិត ។

## សហគមន៍ និង បរិបទ

ទោះជាកម្មវិធីសិក្ខាសាលា ស្ទើរតែដូចគ្នាបេះបិទនៅតាមប្រទេសនីមួយៗ ប៉ុន្តែគ្រប់សិក្ខាសាលាទាំងអស់ធ្វើឡើងអាស្រ័យតាមបរិបទនៃប្រទេសនីមួយៗផងដែរ ។ ជាឧទាហរណ៍ នៅប្រទេសហ្វីលីពីន អ្នកចូលរួមបានយល់ដឹងខ្លះមកហើយអំពីឧបករណ៍វិភាគរបរចិញ្ចឹមជីវិត ដូច្នេះយើងផ្តោតតែលើទិដ្ឋភាពនៃការទំនាក់ទំនងច្រើនជាងឧបករណ៍ជាក់ស្តែង ។ នៅប្រទេសផ្សេងទៀត ឧបករណ៍ PRA ជាឧបករណ៍ថ្មីនៅឡើយ ដូច្នេះយើងចំណាយពេលច្រើនពិភាក្សាអំពីរបៀបប្រើប្រាស់ និងសារៈប្រយោជន៍របស់វា ។ យើងអាចធ្វើការរៀបចំ និងកែលំអ ដោយដកស្រង់នូវវាលការវាយតំលៃនៃសិក្ខាសាលានីមួយៗ ។

កំឡុងពេលសិក្ខាសាលាយើងបានធ្វើទស្សនៈកិច្ចសហគមន៍ចំនួន ៥: Talokgangan ប្រទេសហ្វីលីពីន, Jabarrah ប្រទេសឥណ្ឌា, Nam Houm ប្រទេសឡាវ, Chaung Wa ប្រទេសភូមា និងយូណាន Jinfuzhuangxiaozhai ប្រទេសចិន ។ ការធ្វើទស្សនៈកិច្ចទាំងនេះបានអនុញ្ញាតិឱ្យអ្នកចូលរួមអនុវត្តជាក់ស្តែងនូវឧបករណ៍វិភាគរបរចិញ្ចឹមជីវិតជាមួយសមាជិកសហគមន៍ ។

កន្លែងនីមួយៗប្រជាជនបានប្រាប់យើងដោយសប្បុរសអំពី ជីវិតរបស់ពួកគេ ហើយធ្វើឱ្យអ្នកចូលរួមក្នុងការស្តាប់ប្រជាកសិករ ។ ដើម្បីទទួលពត៌មានបន្ថែមអំពីសហគមន៏អ្នកចូលរួមយល់យ៉ាងច្បាស់អំពី របៀបរៀនសូត្រ និងទំនាក់ទំនងអំពីជីវិតរស់នៅរបស់ប្រជាជន ។

**កំណត់សំគាល់អំពីការពង្រឹងសមត្ថភាព**

គោលបំណងនៃដំណើរការដែលរៀបរាប់ក្នុងក្នុងអត្ថបទនៃទស្សនាវដ្ដីលេខនេគឺពង្រឹងសមត្ថភាពភ្នាក់ងារ និងស្ថាប័នដើម្បីអនុវត្តការវិភាគរបរចិញ្ចឹមជីវិដោយប្រើប្រាស់ឧបករណ៏ PRA ។ វាត្រូវបានគេយល់ថាមានចំណេះដឹងពីរផ្សេងៗគ្នា ។ ន័យទី ១ ទាក់ទងនឹងចំណេះដឹង ដូចការយល់ដឹងសាមញ្ញៗដូចសមត្ថភាព ឬជំនាញ ឧទាហរណ៏ ការបង្កើតឱកាសសំរាប់អ្នកចូលរួមសិក្សាអំពីជំនាញចាំបាច់ដើម្បីធ្វើការវិភាគរបរចិញ្ចឹមជីវិតដោយមានការចូលរួម ។ ន័យទី ២ បានមកពីការយល់ដឹងអំពីតួនាទី ឧទាហរណ៏: សមត្ថភាពដែលបុគ្គលធ្វើការងារ ។ ការចាប់ផ្តើមអំពីការវិភាគរបរ ចិញ្ចឹមជីវិតដោយមានការចូលរួមមានន័យថា អ្នកចូលរួមនឹងបំពេញតួនាទីថ្មីក្នុងការងាររបស់ពួកគេ ដែលមិនធ្លាប់មានពីមុនមក ។ ឧទាហរណ៏: ការសិក្សាអំពីរបៀបឱ្យក្លាយជាអ្នកសំរបសំរួលក្រុម, បន្សាំនឹងឧបករណ៏ និងរបៀបសហការជាមួយអ្នកពាក់ពន្ធ័ថ្មីៗ ។


*អ្នកនិពន្ធ និង កសិករ ឡាលីតា នៅ Jabarrah, West Bengal, India*

Kath Copley and William Savage មានជំនាញផ្នែកទំនាក់ទំនងជាមួយ គំរោង STREAM ហើយជាប់កិច្ចសន្យាជាមួយ FAO គឺជាគ្រូបណ្តុះបណ្តាលប្រពន្ធ័របរចិញ្ចឹមជីវិតថ្នាក់តំបន់ ។ អាស័យដ្ឋានរបស់ពួកគេគឺ kcopley@smartchat.net.au និង
savage@loxinfo.co.th

# ការជ្រើសរើសជំហានដើម្បីឱ្យប្រពន្ធ័ការចិញ្ចឹមជីវិតមានដំណើរការ

*Erwin L Pador*

## យុទសាស្រ្ត និងសកម្មភាព

យុទ្ធសាស្រ្តមួយដែលប្រើប្រាស់ដោយគំរោងអភិវឌ្ឍន៍ជាច្រើនដើម្បីកាត់បន្ថយភាពក្រីក្រគឺ " ការផ្តល់ជារបរចិញ្ចឹមជីវិត " ។ នេះជាការផ្តល់នូវមុខរបរបន្ថែមដល់កសិករក្រីក្រដែលពឹងផ្អែកលើធនធានវារីជាតិ ឬគ្រាន់តែផ្តល់ជាជំរើសធ្វើឱ្យប្រជាសោទងាកចេញឆ្ងាយ ពីការនេសាទជាបណ្តោះអាសន្ន ខណៈដែលធនធានមានការកើតឡើងវិញនៅពេលណាមួយនោះ ។ យុទ្ធសាស្រ្តនេះ វាដូចជាពុំមានបញ្ហាថាតើវាមានភាពថ្លៃថ្នូរ ឬបញ្ចូលនូវអ្វីដែលថ្មីយ៉ាងដូចម្តេច ហើយជានិច្ចកាលពុំទទួលបានជោគជ័យក្នុងដំណោះស្រាយនៃភាពក្រីក្រ និងធ្វើឱ្យគំរោងមានផលចំណេញ ឬក្នុងការគាំទ្រប្រជាជនឱ្យទទួលបាននូវគោលដៅចិញ្ចឹមជីវិតរបស់ពួកគេ ។ វាពិតជាមានការខ្វះខាតក្នុងជំហានជាយុទ្ធសាស្រ្តកំពុងប្រើប្រាស់ ហៅថា សកម្មភាពរបរចិញ្ចឹមជីវិត ដែលជានិច្ចកាលពុំមាននិរន្តភាព ។ ដោយយល់ឃើញយ៉ាងដូច្នេះ ការិយាល័យ STREAM នៃប្រទេសហ្វីលីពីន ស្ថិតក្នុងនាយកដ្ឋានជលផល និងធនធានវារីជាតិ តំបន់ទី ៦ (BFAR) បានផ្តល់ទីកន្លែងសំរាប់ធ្វើសិក្ខាសាលាជាលើកដំបូងអំពី របរចិញ្ចឹមជីវិត និងការវិភាគ ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៣ ។

## ជំហានដំបូង



ការពន្យល់ប្រជាជនអំពី របរចិញ្ចឹមជីវិតនៅភូមិ Talokgangan ឈូងសមុទ្រ Banate

សិក្ខាសាលាមានបំណងបង្កើតជាក្រុមដែលអាចធ្វើការជាមួយ របរចិញ្ចឹមជីវិតទាំងមូល និងតាមរបៀបអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ។ អ្នកចូលរួមមានអ្នកនេសាទល្អ១ចំរុះគ្នា ( ប្រុស, ស្រី), អ្នកបង្កើតសហគមន៍, ប្រធានក្រុមប្រឹក្សាគ្រប់គ្រងឈូង សមុទ្រ, មន្ត្រីសង្កាត់ជលផល, បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីមកពី BFAR ។ សិក្ខាសាលាបានធ្វើឱ្យអ្នកចូលរួម អាចចែករំលែក និងស្វែងយល់អត្ថន័យនៃពាក្យ "ជីវភាពរស់នៅ, របរចិញ្ចឹមជីវិត និងការវិភាគរបរចិញ្ចឹមជីវិត" ។

ការយល់ដឹងអំពីនិរន្តរភាពនៃការចិញ្ចឹមជីវិត ធ្វើឱ្យអ្នកចូលរួមសំរេចថា សកម្មភាពជាច្រើនរបស់ប្រជាជននាពេលបច្ចុប្បន្ន ត្រូវបានគេធ្វើរួចជាស្រេច ពួកគេគ្រាន់តែសាកសួរនូវអ្វីដែលកសិករចង់បានដោយពិតប្រាកដ ។ របរចិញ្ចឹមជីវិតដែលបានពិភាក្សា និងប្រើប្រាស់ក្នុងពេលធ្វើទស្សនៈកិច្ចឈូងសមុទ្រ ធ្វើឱ្យអ្នកចូលរួមយល់កាន់តែច្បាស់អំពីឧបករណ៍ ដែលជាចំណាប់ផ្តើមនៃការគិតគូរអំពី ការគ្រប់គ្រងធនធានសមុទ្រ ។ ឧបករណ៍ទាំងនេះអាចឱ្យយើងមើលឃើញនូវប្រភពធនធាន និងសមត្ថភាពដែលប្រជានេសាទមានរួចជាស្រេចទៅហើយ ហើយវាជាកត្តាជះឥទ្ធិពលលើករិតជីវភាពរបស់ពួកគេ ។

មានការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការបង្កើតក្រុមរបរចិញ្ចឹមជីវិត ព្រោះវាត្រូវបានគេទទួលស្គាល់ថាមានវិស័យច្រើនជាប់ពាក់ពន្ធ័ក្នុងការងារជលផល និងសហគមន៍ធនធានវារីជាតិ ។ គំរោងរបរចិញ្ចឹមជីវិតជាច្រើនរបស់ BFAR ត្រូវបានធ្វើការវាយតំលៃតាមសមត្ថភាពបច្ចេកទេសដែលមាន គឺដោយសារស្ថាប័ននេះជាអង្គភាពបច្ចេកទេសធ្វើការអភិវឌ្ឍន៍វិស័យជលផល ប្រកបដោយនិរន្តភាព ។ អ្វីដែល

គំរោងលើកស្ទួយក៏រិតជីវភាពប្រជាជនកំពុងតែដំណើរការនោះគឺ ពួកគេផ្តោតលើ បញ្ហាសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ។ អ្នកបង្កើតសហគមន៍ និងអ្នកនេសាទគួរតែដឹង និងយល់អំពីតួនាទីរបស់ពួកគេឱ្យបានច្បាស់ ជាពិសេសស្ថានភាពរបស់ពួកគេផ្ទាល់ ។

ការប្រកាន់យកគោលការណ៍របបចិញ្ចឹមជីវិត និងធ្វើការវិភាគ មិនមែនជាវិធីសាស្ត្រធម្មតាសំរាប់អ្នកចូលរួមនោះ វាគួរតែមាននិត្តិវិធីត្រឹមត្រូវ ដែលបុគ្គល ឬអង្គភាព អាចអនុវត្តតាមយន្តការដ៏សមស្របមួយដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ប្រជានេសាទក្រីក្រ ។ ដូច្នេះគេក៏បង្កើតជាពង្រាងគំរូស្តីពី " គោលការណ៍ណែនាំរបបចិញ្ចឹមជីវិត និងការវិភាគ " គោលការណ៍ណែនាំត្រូវបានយល់ព្រម និងអនុវត្តដោយក្រុមសំរបសំរួលរបបចិញ្ចឹមជីវិត សហការជាមួយ ការិយាល័យ STREAM ប្រទេសហ្វីលីពីន ។ គោលការណ៍នឹងបង្ហាញពីព្រំដែននៃរបបចិញ្ចឹមជីវិត និងឧបករណ៍សំរាប់អ្នកប្រើប្រាស់ក្នុងគោលបំណងជាក់លាក់របស់ពួកគេ ហើយវាក៏បង្ហាញផងដែរអំពីវិធីសាស្ត្រ នៃការវិភាគរបបចិញ្ចឹមជីវិត ដោយគិតគូរ និងបង្កើតតំបន់ពិសេសដូចជា ប្រជាជន និងសហគមន៍ ។ គោលកាណ៍នឹងមានលំអិតទុនដែលបានមកពីក្រុមសំរបសំរួលរបបចិញ្ចឹមជីវិតផ្សេងៗគ្នា ហើយបន្ថែមខ្លឹមសារដោយអ្នកពាក់ពន្ធ័ទាំងអស់ ដែលទាំងនេះវានឹងផ្តល់នូវឧបករណ៍ដ៏មានតំលៃសំរាប់គំរោងគាំទ្ររបបចិញ្ចឹមជីវិតនៅទូទាំងប្រទេស ។

**ជំហានបន្ទាប់**

ទោះជាយ៉ាងណាក្តី គោលការណ៍របបចិញ្ចឹមជីវិត បានក្លាយជាចំនុចមួយ ក្នុងចំណោមចំនុច៣ទៀតនៃគំរោង STREAM — ស្ថាបន័, បង្កើតគោលនយោបាយ និងការទំនាក់ទំនង ដែលបានផ្តល់ការគាំទ្រពីគ្នាទៅវិញទៅមក ។ សមិទ្ធផលបន្ទាន់របស់សិក្ខាសាលាគឺ ការភ្ជាប់ទំនាក់ទំនង ជាមួយក្រុមសំរបសំរួលរបបចិញ្ចឹមជីវិត ដើម្បីធ្វើការសិក្សាលើការជួលដូរប្រភេទត្រីលំអ និងការជះឥទ្ធិពលរបស់វាលើជីវ-ភាពប្រជាជនក្រីក្រ ។ STREAM-CHM ប្រទេស ហ្វីលីពីន បានធ្វើការសំរបសំរួលជាមួយការិយាល័យ STREAM ថ្នាក់តំបន់ ហើយទទួលបានជាអ្នកសំរបសំរួលក្នុងសិក្ខាសាលាស្រដៀងគ្នានេះដែរនៅប្រទេស ឥណ្ឌា, ឡាវ និងឥណ្ឌូនេស៊ី ។ ចំណេះដឹង និងជំនាញត្រូវបានចែករំលែកដល់សិក្ខាម ហើយបទពិសោធន៍ដែលកើនឡើង ត្រូវបានផ្តល់ជារង្វាន់ក្នុងអត្ថន័យនៃការយល់បានច្បាស់លាស់អំពី ការចិញ្ចឹមជីវិតនៅតំបន់អាស៊ីប៉ាស៊ីភិច ។

នៅ BFAR ការផ្សព្វផ្សាយមានការយឺតយ៉ាវក្នុងការពិនិត្យមើលឱ្យបានស៊ីជំរៅនូវសកម្មភាពនៃការចិញ្ចឹមជីវិត ។ ការយល់ដឹងនេះអាចមាននិរន្តភាពតាមរយៈក្រុមសន្ទនាជាមួយមន្ត្រី BFAR ដែលមានឥទ្ធិពលលើគំរោងគាំទ្រការចិញ្ចឹមជីវិត ជាពិសេសក្នុងតំបន់ Sapian ។ សកម្មភាពនៃរបបចិញ្ចឹមជីវិត បានអនុវត្តយ៉ាងសកម្មដោយមានការជួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៏អាស៊ី ។ ដោយធ្វើការសហការជាមួយអ្នកបង្កើតសហគមន៍ គេសង្ឃឹមថា តំរូវការរបស់ប្រជាជននឹងត្រូវបានកំណត់ និងស្នើរឡើងដោយប្រើគោលការណ៍ របបចិញ្ចឹមជីវិតដែលបានចាប់ផ្តើមដោយគំរោង STREAM ។

អ្នកនេសាទដែលបានចូលរួមក្នុងអង្គសិក្ខាសាលា មានការពេញចិត្តយ៉ាងខ្លាំងចំពោះគោលការណ៍របបចិញ្ចឹមជីវិត និងឧបករណ៍វិភាគដែលពួកគេបានជួបប្រទះ ជាពិសេសក្នុងកំឡុងពេលធ្វើទស្សនៈកិច្ចតាមបណ្តាសហគមន៍ ។ ពួកគេបានធ្វើការវិភាគច្រើនអំពីស្ថានភាពធនធានជុំវិញសហគមន៍របស់ពួកគេ, អំពីគោលនយោបាយគាំទ្រជីវភាពរបស់ពួកគេ, និងឱកាសនិងការគំរាមកំហែងដែលអាចមាន

ឥទ្ធិពលលើការរស់នៅរបស់ពួកគេ ។ ពួកគេមានការយល់ដឹងច្រើនអំពីអ្វីដែលពួកគេចង់បាន និងអ្វីដែលត្រូវការពិតប្រាកដ ។ ពួកគេជាគូរដឹសកម្មក្នុងការអភិវឌ្ឍន៍វិស័យជលផលរបស់យើង ។

**ត្រូវការជំហានជាច្រើនទៀត**

គ្រប់អ្នកចូលរួមទាំងអស់មានសុទិដ្ឋិនិយមយ៉ាងខ្លាំងបន្ទាប់ពីសិក្ខាសាលារួចមក ។ ពួកគេមានទស្សនៈយ៉ាងច្បាស់លាស់ ថាតើគួរ ដោះស្រាយកិច្ចការចិញ្ចឹមជីវិតរបស់ពួកគេដោយរបៀបណា ។ សិក្ខាសាលស្តីពី គោលករណ៍ចិញ្ចឹមជីវិត និងការវិភាគ ធ្វើឱ្យក្របខណ្ឌនៃ ការចិញ្ចឹមជីវិតមាននិរន្តភាព និងមានរបៀបរៀបរយ ។ ទោះជាយ៉ាងណាក្តី ការរំភើបរបស់អ្នកចូលរួមមិនយឺតពេលនោះទេ ខណៈដែលយន្តការនិរន្តភាពដូចជាគោលការណ៍ណែនាំកំពុងតែធ្វើការកែលំអ ។ ការកែលំអ និងប្រើប្រាស់គោលការណ៍ណែនាំ ជាងនឹងត្រូវបានផ្តោតលើស្ថាបន័ និងអ្នកពាក់ពន្ធ័ដែលមានការគាំទ្រគោលការណ៍ចិញ្ចឹមជីវិត ។ អ្នកចូលរួមយល់ឃើញថា ការជួយទ្រទ្រង់ចំពោះគោលការណ៍បែបនេះ ត្រូវតែធ្វើឡើងដោយប្រសិទ្ធិភាពតាមវិធីសាស្រ្តដែលធ្វើឡើងដោយ ពចៅ្រ និងស្ថាបន័ផ្សេងៗទៀត ។

ការបន្តភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍តំបន់សមុទ្រ និងសហគមន៍ធនធានវារីជាតិដទៃទៀត អាចជួយយើងយល់ច្បាស់ថា ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព វាមិនត្រឹមតែផ្តោតលើធនធានប៉ុណ្ណោះទេ តែត្រូវយកប្រជាជនជាធំដើម្បីប្រើប្រាស់ធនធាន, ពង្រឹងសមត្ថភាពពួកគេឱ្យក្លាយជាអ្នកកាន់កាប់ធនធានដោយខ្លួនឯង ។ នេះជាបញ្ហាជាក់ស្តែង ។

Erwin L Padorគឺជាជំនួយការសំរបសំរួលថ្នាក់ជាតិនៃគំរោង STYREAM ប្រចាំប្រទេសហ្វីលីពីន នៃនាយកដ្ឋានជលផល និងធនធានវារីជាតិ ប្រចាំតំបន់ ៦ ក្នុងទីក្រុង Iloilo ។ គាត់អាចទំនាក់ទំនងតាមអាស័យដ្ឋាន epador@bfar.da.gov.ph

# ការឆ្លុះបញ្ចាំងសិក្ខាសាលានៅប្រទេស ឥណ្ឌា-នេប៉ាល់

ដោយ Rubu Mukherjee និង Nilkanth Pokhrel

## សហសេវិកនេប៉ាល់ធ្វើទស្សនៈកិច្ចនៅ Ranchi និង Jabarrah

GVT[1]/NACA-STREAM/FAO សិក្ខាសាលាថ្នាក់អន្តរជាតិអំពី គោលការណ៍របរចិញ្ចឹមជីវិតនិងការវិភាគ បានប្រារព្ធឡើងនៅ Ranchi ប្រទេសឥណ្ឌា ក្នុងខែកុម្ភៈ ឆ្នាំ ២០០៤ ។ មានអ្នកចូលរួមចំនួន ៩នាក់ តំណាងឱ្យនាយកដ្ឋានជលផលនៅ Jharkhand, Orissa និងរដ្ឋ West Bengal និង ការិយាល័យSTREAMប្រចាំប្រទេសឥណ្ឌា ។
សិក្ខាសាលាក៏ត្រូវបានចូលរួមដោយសហសេវិកមកពី ប្រទេសនេប៉ាល់ ដោយធ្វើដំណើរតាមផ្លូវគោកមកកាន់ Ranchi ពួកគេតំណាងឱ្យមជ្ឈមណ្ឌលកសិកម្មស្រុក និងការិយាល័យជលផល ។

ក្នុងពេលធ្វើសិក្ខាសាលាយើងបង្កើតឱ្យមានទស្សនៈកិច្ចសិក្សាតាមសហគមន៍ក្នុងភូមិមួយមានឈ្មោះថា Jabarrah ក្នុងរដ្ឋ Bengal ខាងលិច ។ តាមរយៈការពិភាក្សាជាមួយអ្នកនេសាទ និងកសិកររួចមក យើងបានដឹងពីរបៀបនៃការផ្លាស់ប្តូរក៏រិតជីវភាពរបស់ពួកគេនៅទីនោះ បន្ទាប់ពីពួកគេមានការជាប់ពាក់ពន្ធ័ជាមួយការងារវារីវប្បកម្ម ។



ទិដ្ឋភាពនៃការធ្វើទស្សនៈកិច្ចសហគមន៍នៅ *Jabarrah, West Bengal*

[1] Gramin Vikas Trust, an NGO partner of STREAM in India

**មុន និងក្រោយសិក្ខាសាលា**

មុនពេលចូលរួមសិក្ខាសាលាយើងទាំងអស់គ្នាបានយល់រួចមកហើយនូវពាក្យ ការចិញ្ចឹមជីវិត (Livelihoods) ។ ក្នុងន័យនេះយើងបានឱ្យនិយមន័យថា ការចិញ្ចឹមជីវិតគឺជា "មធ្យោបាយរស់នៅរបស់មនុស្សម្នាក់" ។ ទោះជាយ៉ាងណា បន្ទាប់ពីចូលរួម ក្នុងសិក្ខាសាលារួចមក យើងបានយល់ស៊ីជំរៅជាងនេះបន្តិចគឺវាមានន័យទូលាយជាង មធ្យោបាយរស់នៅរបស់មនុស្សម្នាក់ ព្រោះវាបានផ្សារភ្ជាប់ជាមួយអ្នកដទៃទៀតរួមមាន សង្គមទាំងមូល, ក្រុមផ្សេងៗគ្នា និងបុគ្គលផ្សេងៗទៀត ពោលគឺពួកគេមានទំនាក់ទំនងរវាងគ្នាទៅវិញទៅ មក ។

នៅពេលត្រលប់ទៅកន្លែងធ្វើការវិញ យើងបានចាប់ផ្តើមចែករម្លែកចំណេះដឹងដែលបានមកពីសិក្ខាសាលា ដល់សមាគមរបស់យើង ។ នៅប្រទេសឥណ្ឌាមន្ត្រីនាយកដ្ឋានជលផល នៃរដ្ឋ Jharkhand បានបន្តការសិក្សារៀនសូត្រអំណពីរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលជាប់ពាក់ពន្ធ័ជាមួយការគ្រប់គ្រងធនធានវារីជាតិ ។ ពួកគេបានប្រមូល “significant change stories”ពីប្រជានេសាទ និងកសិករ ហើយផ្សព្វផ្សាយដល់កសិករក្នុងតំបន់ដ៏ទៃទៀត ។

លោក Ravi Shankar មន្ត្រីជលផលស្រុកមកពី Ranchi, Jharkharnd បាននិយាយថា បន្ទាប់ពីចូលរួមសិក្ខាសាលារួចមក ដំណោះស្រាយរបស់យើងត្រូវបានកែប្រែ ។ សិក្ខាសាលាមានឥទ្ធិពលជាច្រើនលើពួកយើង ជាពិសេសនៅពេលពួកយើងភ្ជាប់ទំនាក់ទំនងជាមួយដៃគូរបស់យើងមកពីប្រទេសនេប៉ាល់ ។ យើងមានការយល់ដឹងយ៉ាងច្រើនអំពីគោលការណ៍របរចិញ្ចឹមជីវិត ។

ចំពោះផ្នែករបស់ពួកគេ ក្រុមនេប៉ាល់បានបង្ហាញពីឆន្ទរបស់ពួកគេក្នុងការចែករំលែកចំណេះដឹងដែលទទួលបានពីប្រទេស និងសហគមន៍ជនបទ តាមរយៈការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុអំពី មជ្ឈមណ្ឌលពតិមានកសិកម្ម ។ ពួកគេបានសំដែងនូវការចាប់អារម្មណ៏ក្នុង ការបង្កើត ឱ្យមានជាប្រចាំនូវកម្មវិធី របរចិញ្ចឹមជីវិតរបស់នាយកដ្ឋានជលផលក្នុងប៉ុន្មានឆ្នាំបន្តទៀត ហើយយ៉ាងហោចណាស់ធ្វើគំរោងការសាកល្បងចំនួន ១ ។




តើយើងត្រូវការអ្វីខ្លះដើម្បីស្វែងយល់អំពីរបៀបនៃការរស់នៅរបស់ប្រជាកសិករ ?

# ការឆ្លុះបញ្ចាំងអំពីតួនាទីរបស់គោលការណ៍របរចិញ្ចឹមជីវិត និងការវិភាគនៅប្រទេសឡាវ

ដោយ *Phanthavong Vongsamphanh and Graham Haylor*

## STREAM ជំហានដំបូងនៅប្រទេសឡាវ

នៅខែមិនា ឆ្នាំ ២០០៤ នាយកដ្ឋានបសុព្យាបាល និងជលផលរបស់រដ្ឋាភិបាលឡាវ, NACASTREAM និង អង្គការ FAO ធ្វើសិក្ខាសាលាមួយស្តីពី របរចិញ្ចឹមជីវិត និងការវិភាគ នៅទីក្រុងវៀងចន្ទ ។ នេះជាសិក្ខាសាលា និងព្រឹត្តិការណ៍ជាលើកដំបូងរបស់ STREAM នៅប្រទេសឡាវ ដោយមានការចូលរួមពីមន្ត្រីនៅក្រុងវៀងចន្ទ និងតាមបណ្តាខេត្តចាច្រើនទៀតនៅទូទាំងប្រទេស ។ ក្នុងសប្តាហ៍នោះ យើងចំណាចពេលយ៉ាងច្រើនដើម្បីបង្ហាញពីភាពសាំញ៉ាំរបសហ់សហគមន៍ និងក្រុមកសិករដែលយើងបានធ្វើការជាមួយ និងចែករំលែកនូវចំណេះដឹងអំពីថា តើយើងយល់អំពីការចិញ្ចឹមជីវិតល្អដល់កំរិតណា ។



ការធ្វើផែនទីសង្គមកំឡុងពេលធ្វើការវិភាគរបរចិញ្ចឹមជីវិតនៅណាមហួន

ក្បែរទីក្រុង វៀនចន្ទ

សមាសភាពសំខាន់របស់សិក្ខាសាលាគឺការធ្វើទស្សនៈកិច្ចនៅណាមហួន ជាកន្លែងដែលអ្នកចូលរួមបានអនុវត្តសកម្មភាព និងសិក្សាអំពីការចិញ្ចឹមជីវិតរបស់សហគមន-នៅទីនោះ ។ លើសពីនេះដើម្បីបង្កើនពតិមានក្នុងសហគមន៏ ណាមហួនដោយខ្លួនឯងនោះអ្នកចូលរួមបានមើលឃើញថាតើពួកគេវិភាគ ការចិញ្ចឹមជីវិតដល់កំរិណា ។ លទ្ធផលសិក្ខាសាលាពីប្រទេសហ្វីលីពីន និងឥណ្ឌា (ជាមួយ នេប៉ាល់) រួមមានពង្រាងសង្ខេបអំពី គោលការណ៏ណែនាំការវិភាគរបរចិញ្ចឹមជីវិត ដែលត្រូវធ្វើការកែប្រែសំរាប់ប្រទេសឡាវក្នុងពេលសិក្ខាសាលានេះ ។ ពង្រាងសង្ខេបបានបញ្ចូលមេរៀនជាបទពិសោធន៏បានមកពីការធ្វើទស្សនៈកិច្ចនៅសហគមន៏ ណាមហួន ហើយនឹងធ្វើការបន្តដោយលំអិត ជាងនេះក្នុងសិក្ខាសាលាស្តីអំពី គោលការណ៏ណែនាំ ការវិភាគរបរចិញ្ចឹមជីវិត លើកក្រោយទៀត ។

## ការស្វែងយល់ និងឆ្លុះបញ្ចាំងការចិញ្ចឹមជីវិតក្នុងបរិបទប្រទេសឡាវ

នៅប្រទេសឡាវ ជាពិសេសនៅថ្នាក់ស្រុក មនុស្សភាគច្រើនធ្វើការជាមួយនាយកដ្ឋានបសុព្យាបាល និងជលផល ពួកគេគឺជាសមាជិកកសិដ្ឋាន និងសហគមន៏នេសាទ ដែលពួកគេជាមន្ត្រីរដ្ឋាភិបាល ។ ទាំងនេះធ្វើឱ្យពួកគេមើលឃើញកាន់តែច្បាស់អំពីការរស់នៅ និងការចិញ្ចឹមជីវិតរបស់ប្រជាជនដែលពួកគេមានបំណងចង់គាំទ្រ ។ ចំពោះគំនិតដែលយកប្រជាជនជាធំនៃការអភិវឌ្ឍន៏នោះជាការប្រកបដោយអំណាចអព្ភូតរញ្ញាណ ចំពោះមនុស្សភាគច្រើន ។ ចំពោះមន្ត្រីទាំងនោះវាជាវិធីដែលគេបានធ្វើរួចទៅហើយ ដូច្នេះក្របខណ្ឌ័នៃការវិភាគរបរចិញ្ចឹមជីវិតដែលពិភាក្សាក្នុងសិក្ខាសាលាគឺគ្រាន់តែជួយផ្តល់ជារចនាសម្ពន្ធ័ និងភាពម៉ឺងម៉ាត់នៃដំណើរការរបស់ពួកគេ ។

បណ្ឌិត Singkham Phonvisay ប្រធាននាយកដ្ឋានជលផល បានគូសបញ្ជាក់អំពីសារៈសំខាន់ នៃវិស័យជលផលចំពោះប្រជាជន ឡាវ និងធ្វើការផ្លាស់ប្តូរមួយចំនួនដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព:

*ប្រវត្តិនៃការចិញ្ចឹមជីវិតរបស់ប្រជាជនឡាវស្ទើរតែទាំងស្រុងពឹងផ្អែកលើធនធានវារីជាតិ ។ ប៉ុន្តែបច្ចុប្បន្ន ប្រជាជនមាន ការកើនឡើង ឧបករណ៍នេសាទទំនើប១ហើយត្រូវបានគេប្រើប្រាស់យ៉ាងទូលាយទៀតផង ។ នៅពេលនោះដែរ ធនធានជលផលមានការថយចុះ និងមានដោយកម្រទៀតផង ។ ប្រពន្ធ័នៃការចិញ្ចឹមជីវិតរបស់ពួកគេមិនទាន់មានការកែលំអនៅឡើយហើយប្រជាជននៅតែពងផ្អែកលើធនធានធម្មជាតិ ។ ដូច្នេះយើងគួរមានគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងធនធានវារីជាតិដើម្បីនាំប្រជាជនឆ្ពោះទៅកាន់ជីវភាពមួយប្រកបដោយនិរន្តភាព ។*

ឆ្លុះបញ្ជាំងលើគោលការណ៍ និងការវិភាគក្នុងបរិបទប្រទេសឡាវយើងឃើញថា មន្ត្រីទាំងនោះមានចំណាប់អារម្មណ៍ថា វាត្រូវការពេលវេលាដើម្បីបង្កើតចំណេះដឹងអំពីឧបករណ៍ការចិញ្ចឹមជីវិត និងស្វែងយល់ពីវិធីសាស្ត្រសួរសំណួរ, របៀបអង្កេតឱ្យល្អជាងនេះ និងរបៀបវិភាគពត៌មាន ។ ជាពិសេសមន្ត្រីភាគច្រើនមានបំណងចង់កែលំអសមត្ថភាពសរសេររបាយការណ៍, ប្រើវិធីសាស្ត្របត់បែន ដើម្បីវិភាគការចិញ្ចឹមជីវិត និងការបកស្រាយ ដែលជាចំណេះដឹងថ្មី១សំរាប់ពួកគេ ។ ទិដ្ឋភាពគួរចាប់អារម្មផ្សេងទៀតគឺរកវិធីសាស្ត្រណា ឬលើកទឹកចិត្តប្រជាជនក្នុងសហគមន៍ និយាយឱ្យបានច្រើននិងយូរ ក្លាយជាមិត្តភាព និងកសាងការទំនាក់ទំនង និងដើម្បីអាចរកឱ្យឃើញ នូវការពិតនៃជីវិតរស់នៅរបស់ប្រជាជន ។




ការបរិយាយរបស់ក្រុមមួយអំពី ការចិញ្ចឹមជីវិត

លោកស្រី Nouhak Liabvixay, ប្រធានសំរបសំរួលគំរោង ផ្សព្វផ្សាយ និងកែលំអវារីវប្បកម្មនៅក្រុងវៀងចន្ទ័មានប្រសាសន៍ថាៈ

*រឿងមួយគួរឱ្យអស្ចារ្យចំពោះការប្រើឧបករណ៍ PRA គឺពេលដែលយើងពន្យល់ដល់ក្រុមនោះពួកគេអាចប្រើវាបានហើយស្ថិតក្រោមការពិនិត្យយ៉ាងល្អ ពួកគេមិនមែនជាអ្នកសួរសំណួរទេ ។ បញ្ជើរសំណួរដូចជាមានលក្ខណៈផ្លូវការបន្តិចប្រជាជនមានការភ័យខ្លាច ។ ពេលពួកគេជាប់រវល់ក្នុងកិច្ចការនេះវាក្លាយជាមិនផ្លូវការទៅវិញ ។ ដូច្នេះពតិមានអាចលំអៀត និងទូលាយជាង ។ ចំណែកឯបញ្ជើរសំណួរត្រូវចេះបត់បែន ហើយឧបករណ៍ PRA ជូនកាលធ្វើឱ្យយើងទទួលបាននូវពត៌មានថ្មី ដែលយើងមិនបានស្មានទុកជាមុន ។*

លោក Somphanh Champengxay, ប្រធានសំរបសំរួលថ្នាក់ជាតិនៃគំរោង STREAM ក្នុងប្រទេសឡាវមានប្រសាសន៍ថា :

*ការវិភាគការចិញ្ចឹមជីវិតមិនមែនជាបញ្ហាងាយស្រួលនោះទេ ជាពិសេសចំពោះមន្ត្រីធ្វើការនៅតំបន់ដាច់ស្រយាល និងជាមួយប្រជាជនតាមជនបទ វាជាការពិបាកក្នុងការស្វែងយល់អំពីការចិញ្ចឹមជីវិតរបស់ពួកគេ ។ ការសិក្សាស្វែងយល់អំពីការវិភាគការចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងតំបន់ផ្សេងៗគ្នាជាគន្លឹះយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលប្រទេសឡាវ ដែលមានបំណងកែលំអកំរិតជីវភាព របស់ប្រជាជនក្រីក្រ ។*

លោក Phanthavong Vongsamphanh ធ្វើការនៅនាយកដ្ឋានជលផល និងបសុព្យាបាល ក្រុងវៀងចន្ទ៍ ប្រទេសឡាវ ។ លោកអាចទំនាក់ទំនងតាមរយៈ អ៊ីមែលៈ pvongsamphanh@yahoo.com លោក Graham Haylor នាយកគំរោងព្រៃ នៅក្រុងបាងកក ប្រទេសថៃ លោកអាចទំនាក់ទំនងតាមរយៈ អ៊ីមែលៈ ghaylor@loxinfo.co.th

## បន្ទាប់ពីសិក្ខាសាលាស្តីពី គោលការណ៍របរចិញ្ចឹមជីវិត និងការវិភាគ

ដោយ *Khin Maung Soe, Aye Aye Zaw, Nilar Kyawen* និង *Myant Thar Htun*

### សិក្ខាសាលា: ការសិក្សាស្វែងយល់ និងតាមដានសកម្មភាព

សិក្ខាសាលរបស់ DoF/NACA-STREAM/FAO ស្តីពី គោលការណ៍របរចិញ្ចឹមជីវិត និងការវិភាគ បានធ្វើឡើងក្នុងក្រុង រ៉ង់ហ្គូន ប្រទេសភូមា ក្នុងខែឧសភា ឆ្នាំ ២០០៤ ។ អ្នកចូលរួមចំនួន ១៨នាក់មកពីក្រុងរ៉ង់ហ្គូន, ម៉ាន់ដាលេ, សាហ្គីន, អាយ៉ាបាឌី និងខេត្តសាន់ប៉ែកខាងត្បូង ។ សិក្ខាសាលបានធ្វើឱ្យសិក្ខាកាមយល់យ៉ាងសាមញ្ញអំពី ការចិញ្ចឹមជីវិត, គោលការណ៍ចិញ្ចឹមជីវិត និងការវិភាគ ។ នៅពេលដំបូងអ្នកចូលរួមមានការចាប់អារម្មណ៍ អំពីការចិញ្ចឹមជីវិតផ្សេងៗពីគ្នា:

- មធ្យោបាយសំរាប់បំពេញតំរូវការប្រចាំថ្ងៃរួមមាន ស្បៀង, សំលៀកបំពាក់ និងទីជំរក ។
- ការប្រកបកិច្ចការរបស់ប្រជាជនដើម្បីរកចំណូលសំរាប់បំពេញតំរូវការទាំងនោះ ។
- ដោះស្រាយបញ្ហា និងការលំបាកសំរាប់តម្រូវការជីវិតប្រចាំថ្ងៃដូចជា ស្បៀង, ទីជម្រក, សំលៀកបំពាក់, ការសិក្សា និងកិច្ចការសង្គមផ្សេងៗទៀត ។ សុភមង្គល និងទុក្ខសោកដែលយើងជួបប្រទះគឺជាផ្នែកមួយនៃការចិញ្ចឹមជីវិត
- ជាការតស៊ូរបស់ប្រជាជនដើម្បីបំពេញតំរូវការប្រចាំថ្ងៃ

នៅចុងបញ្ចប់នៃអង្គសិក្ខាសាលា វាមានការផ្លាស់ប្តូរយ៉ាងច្រើនលើការយល់ឃើញរបស់អ្នកចូលរួម ជាឧទាហរណ៍មកពីអ្នកចូលរួមចំនួនពីរនាក់ដូចខាងក្រោម:

> ពីដំបូងខ្ញុំគិតជាទូទៅថា ការចិញ្ចឹមជីវិតគឺជាជីវិតរាល់ថ្ងៃរបស់មនុស្ស ។ តែឥឡូវខ្ញុំយល់ថា វាគឺជាលទ្ធផលនៃការទំនាក់ទំនងរវាងមនុស្ស, ធនធាន និងគោលនយោបាយ ។ ហើយខ្ញុំយល់យ៉ាងច្បាស់ទៀតថា ការស្វែងយល់អំពីជីវិតពិតប្រាកដរបស់ប្រជាជន នឹងជួយឱ្យយើងធ្វើផែនការបានយ៉ាងល្អសំរាប់អភិវឌ្ឍន៍សហគមន៍ឱ្យស៊ីជំរៅ ។
>
> ខ្ញុំ គិតថាការចិញ្ចឹមជីវិតគឺជាការទំនាក់ទំនងរវាងទ្រព្យសម្បត្តិ, ការអប់រំ និងសមត្ថភាពដើម្បីទទួលបាននូវឱកាសសំរេចមុខជំនួញតែប៉ុណ្ណោះ ។ តាមរយៈមេរៀនជាបទពិសោធន៍ពីសិក្ខាសាល និងការធ្វើទស្សនៈកិច្ចនៅសហគមន៍ ខ្ញុំយល់ឃើញថា ការចិញ្ចឹមជីវិតគឺភាពខុសគ្នាអាស្រ័យដោយមានអន្តរអំពើជាមួយកត្តាផ្សេងៗរួមមាន បំណងប្រាថ្នា, ឱកាសការងារ និងធនធានដែលមាន ។

ក្នុងកិច្ចខំប្រឹងប្រែងដើម្បីកែលំអជីវភាពរស់នៅតាមរយៈការគ្រប់គ្រងធនធានវារីជាតិ សិក្ខាសាលា បានសំរេចធ្វើការតាមដានសកម្មភាពជាច្រើនដោលមានទំនាកលទំនងទៅនឹងការពង្រឹងសមត្ថភាព និងពតិមាន:

1. បង្កើតក្រុមសិក្សាអំពី របរចិញ្ចឹមជីវិត
2. កំនត់តំបន់សិក្សាអត្ថិភាពជាមួយសហគមន៍ដោយភ្ជាប់រួមទាំងការងារជលផល ។
3. ប្រមូលទិន្នន័, ពតិមានដែលត្រូវការ និងកត់ត្រាផលនេសាទដោយផ្តោតលើ កន្លែងនេសាទ, ពេលវេលា, ប្រភេទត្រីចាប់បាន, ឧបករណ៍នេសាទ និងការប្រើប្រាស់, ការកែច្នៃ និងទីផ្សារ ។

4. វិភាគទិន្នន័យ និងពតិមានដើម្បីស្វែងយល់ពីការចិញ្ចឹមជីវិតរបស់ប្រជានេសាទដែលជាប់ពាក់ពន្ធ័នឹងការនេសាទ និងសកម្មភាពផ្សេងៗងទៀត ។
5. វិភាគថាតើសកម្មភាពនេសាទបានគាំទ្រការចិញ្ចឹមជីវិតក្នុងទមបន់ផ្សេងគ្នានៃប្រទេស ។
6. វាយតំលៃធនធានជលផល និងនិរន្តភាពរបស់វាសំរាប់គាំទ្រជីវិភាពរស់នៅរបស់ប្រជាជន ជាពិសេសក្នុងតំបន់មិនសូវមានធនធាន ។

## ការទិតទំប្រឹងប្រែងចំពោះការវិភាគរបរចិញ្ចឹមជីវិត

ក្រុមសិក្សារបរចិញ្ចឹមជីវិត ឬហៅថាក្រុម អាយ៉ាវ៉ាឌី បានចាប់ផ្តើមសិក្សាអំពីការជួលកិច្ចសន្យាវិស័យជលផល នៅអាយ៉ាវ៉ាឌី (តំបន់ទំនាបប្រទេសភូមា) ។ សមជិកទាំងប្រាំរបស់ក្រុមមកពីនាយកដ្ឋានជលផល (ប្រធានការិយាល័យ និងតាមបណ្តាខេត្ត) និងសហពន្ធ័ជលផលនៃប្រទេសភូមា ។ ក្រុមបានចុះទៅ ខូនយ៉ាអ៊ីន ដើម្បីធ្វើការសិក្សាអំពីការជួលកិច្ចសន្យាវិស័យ និងការប្រើប្រាស់ តើធនធានទាំងនេះគាំទ្រដល់ការចិញ្ចឹមជីវិតប្រជាជនយ៉ាងដូចម្តេច និងបញ្ហាក្នុងការគ្រប់គ្រងវីយជលផលឱ្យមាននិរន្តភាព ។

ខូនយ៉ាអ៊ីន ស្ថិតនៅក្នុងខេត្ត ហ៊ិនថាដា, អាយ៉ាវ៉ាឌី ជាប់នឹងទន្លេ អាយ៉ាវ៉ាឌី ហើយភ្ជាប់នឹងស្ទឹង និងព្រែកតូចៗ ។ ទំនប់អាយ៉ាវ៉ាឌីជាផ្លូវដ៏សំខាន់សំរាប់ការធ្វើចរាចររបស់ត្រីតាមតំបន់នេសាទ និងស្ទឹង ។ ផ្ទៃទឹកមានទំហំ ៨០៨ ហិចត័រ ។ នៅផ្នែកកណ្តាលមានផ្ទៃដីទំហំ ២៥៩ អិចត័រ បង្កើតជាស្ទឹង និងប្រពន្ធ័រលកដើម្បីគាំទ្រដល់ការបង្កើតធនធានជលផលដំបូង ។

ឡូតអាជីវកម្មទាំងនោះមានការកើនឡេអរហូតដល់ ៣៨,២% ក្នុងរយៈពេល ៥ឆ្នាំ គឺពី ១៨៧.២០០ ខ្យាត់ (ប្រហែល ១៨៧ ដុល្លារ ក្នុងឆ្នាំ ១៩៩-២០០០ ហើយបានតែ ៧១១.៦០០ខ្យាត់ ឆ្នាំ ២០០៤-០៥ ។ ផលចាប់បានមានការថយចុះ ៣៩% ពី ៣០០តោនឆ្នាំ ៩៩-២០០០ មកត្រឹមតែ ១១៧ តោន ឆ្នាំ ២០០៣-០៤ ។

មន្ត្រីសង្កាត់ជលផលនិយាយថា មុនឆ្នាំ ១៩៩១ មានប្រភេទត្រីប្រហែល ២៣ ប្រភេទរួមមាន: ប្រភេទត្រីកាបចំនួន ៣ប្រភេទ, ត្រីរ៉ស់ ៣ប្រភេទ, ប្រភេទអណ្តែង ៣ប្រភេទ, ប្រភេទកាបកូនកាត់, និងប្រភេទផ្សេងទៀតដូចជា ត្រីក្រាញ់ ត្រីឆ្លូញ ត្រីលំអ ត្រីឆ្តិន និងត្រីខ្ជង់ ។ ទោះជាយ៉ាងនេះក្តី ក្រោយឆ្នាំ ២០០០ ប្រភេទត្រីចាប់បានជាប្រភេទត្រីកាប ។ ម្ចាស់ឡូតទទួលខុសត្រូវក្នុងការលែងពូជត្រីកាបជំនួសការចាប់ ដែលមានតំលៃ១-៥%នៃតំលៃជួលជារៀងរាល់ឆ្នាំ ។ របាយការណ៍នៃការលែងកូនត្រីប្រចាំឆ្នាំជំនួសវិញមានពី ១,៨លានក្នុងឆ្នាំ ២០០១-២០០២ ទៅ ២,៤៩លាន ឆ្នាំ ២០០២-២០០៣ និង១,០៦លានឆ្នាំ ២០០៣-២០០៤ ។

កសិករនេសាទដោយប្រើ មងបណ្តែត, មាញ់, សំណាញ់ និងសន្ទូចរាយ ។ តំបន់នេសាទគ្រប់គ្រងដោយមន្ត្រីរដ្ឋាភិបាលចំនួន ៣៣នាក់ ។ ការនេសាទធ្វើឡើងដោយមានការចូលរួមមនុស្សចំនួន ២២សហការណ៍ជាមួយ ប្រជាជនក្នុងភូមិ ។
ម្ចាស់ឡូតទិញផលនេសាទវិញដោយតំលៃ ០,២៥ដុល្លារ/១០គ.ក្រ ។ អ្នកនេសាទក្នុងភូមិរកចណ្ណូលបានពី ៨០០-១០០ Kyats (០,៨-១,០០ដុល្លារ) និងមានខ្លះហួតដល់ ២០០០ Kyats (២,០០ ដុល្លារ) ក្នុងមួយថ្ងៃ ។ ឡូតនេសាទផ្តល់ជាត្យប្រូតេអ៊ីនដល់ប្រជាជនចំនយន ២២ ០០០នាក់ ក្នុងភូមិចំនួន ៧ ។ ហើយវាក៏ផ្តល់ទឹកសំរាប់ស្រោចស្រពដំណាំបានផ្ទៃដីចំនួន ៧៦៤ acres នៅរដូវប្រាំង ។

មុនឆ្នាំ ២០០០ គេឃើញមានរុក្ខជាតិទឹកជាច្រើនក្នុងតំបន់នេសាទ តែបច្ចុប្បន្ន ឃើញមានតិចតួច ឬឃើញទាល់តែសោះនៅ ពេលថ្មីៗនេះ ។ ដើមក្រចៅឃើញមានដុះច្រើនក្នុងតំបន់ ជារៀងរាល់ឆ្នាំ ។ ជីអសរីរាង្គ និងជីគីមី ដែលប្រើសំរាប់សកម្មភាពកសិកម្មនៅជុំវិញ តំបន់នេសាទ ។ តាមរបាយការណ៍ឱ្យដឹងថា ត្រីស្លាប់ចំនួន ២០០០០ក្បាលនៅឆ្នាំ ២០០២ និង ២៥០០០ ក្បាលនៅឆ្នាំ ២០០៤ ។ យើងបានដឹងទៀតថា គុណភាពទឹកមានការថយចុះយ៉ាខ្លាំង ហើយត្រីស្លាប់ជារៀងរាល់ឆ្នាំ កំឡុងខែ កក្កញ្ញា ដល់តុលា ។



ការនេសាទដោយសំណាញ់

ដើម្បីសងជំនួសការថយចុះផលត្រីក្នុងដែននេសាទ ការអនុវត្តន៏ការលែងពូជត្រីកាបជំនួស ហាក់ដូចជាបានបង្កើតទិន្នផលត្រី ។ ទោះជាយ៉ាងនេះក្តី វាមិនអាចជំនួសឱ្យការបាត់បង់ប្រភេទត្រីក្នុងស្រុកបានទេ ។

ឡូតនេសាទ Duya Inn បានផ្តល់ជាតិប្រូតេអ៊ីនត្រីជាច្រើន និងគាំការចិញ្ចឹមជីវិតដល់អ្នកនេសាទ និងកសិករនៅតំបន់នោះ ។ ទោះជាយ៉ាងណាក៏ដោយ វាបាននឹងកំពុងប្រឈមដោយគុណភាពទឹក, ការកើនឡើងនូវអ្នកប្រើប្រាស់យ៉ាងច្រើនប្រភេទ ហើយប្រភពធនធានចេះតែថយចុះ ។ ដូច្នេះវាត្រូវការជាបន្ទាន់ដើម្បីសិក្សាស្វែងយល់អំពីទំនាក់ទំនងរវាង មជ្ឈដ្ឋានជុំវិញ និងធនធានជលផល និងដើម្បីធ្វើការវាយតំលៃផលប្រយោជន៏លើពូជត្រីកាបក្នុងតំបន់ឡូត ។

អ្នកនិពន្ធគឺជាមន្ត្រីជលផលទាំងអស់ក្នុងនាយកដ្ឋានជលផលនៃប្រទេសភូមា ។Khin Maung Soe ជាអនុប្រធាននាយកដ្ឋានចលផល និងជា CHMs របស់ STREAM ។ Aye Aye Zaw ជំនួយការប្រធាននាយកដ្ឋានជលផលទឹកសាប, Nilar Kyawe មន្ត្រីជលផលទឹកសាប, Myant Thar Htun មន្ត្រីជលផលស្រុក Hinthada ។ ពួកគេអាចទំនាក់ទំនងតាមរយៈអ៊ីមែល: aquadof@mynmar.com.mm

# សារៈសំខាន់របស់គោលការណ៍ចិញ្ចឹមជីវិត នៅយូណាន, ប្រទេសចិន

ដោយ *Susan Li and William Savage*

**ស្រុក Mengzi និង Jinfuzhuangxiaozhai**

NACA-STREAM/FAO បានបើកសិក្ខាសាលាលើកទី ៥ និងចុងក្រោយស្តីពី គោលការណ៍ ចិញ្ចឹមជីវិត និងការវិភាគ នៅស្រុកម៉េងស៊ី, យូណាន ប្រទេសចិន ក្នុងខែកញ្ញា ឆ្នាំ ២០០៤ ។ អ្នកចូលរួមមានចំនួន ៣០នាក់មកពីតំណាងខេត្តចំនួន ៧ ។ សកម្មភាពសង្ខេបក្នុងសប្តាហ៍នោះគឺ ការធ្វើទស្សកិច្ចសហគមន៍នៅភូមិ Jinfuzhuangxiaozhai សហគន៍មួយរបស់ជនជាតិភាគតិច ហានី (HA

## ទស្សនៈវិស័យរបស់អ្នកចូលរួម



សិក្ខាសាលាដ៏ពិសេសនេះបានបញ្ចប់ដោយឆ្លើយតបទៅនឹងសំណួររបស់អ្នកចូលរួមអំពីរបៀបទំនាក់ទំនងនៃការងាររបស់ពួកគេនឹងរបរចិញ្ចឹមជីវិត ។ តាមសំដីផ្ទាល់របស់ពួកគេ និងតំណាងខេត្តរបស់គេតែម្តង

មុននឹងធ្វើការអភិវឌ្ឍន៍គំរោង ជលផល ឬវារីវប្បកម្មមួយ យើងគួរក្រលេកមើលជាទូទៅនូវធនធាន សហគមន៍ និងចាត់ទុកវារីវប្បកម្មជាផ្នែកទាំងមូលនៃការអភិវឌ្ឍន៍ ។ យុទ្ធសាស្ត្រគួរក្រឡេកមើល ធនធានធម្មជាតិ និងធនធានមនុស្ស ហើយធ្វើការប្រៀបធៀបដើម្បីឱ្យវាស៊ីគ្នា ប្រសិនបើមិនស៊ីគ្នាទេនោះ យើងគួរមានកម្មវិធីផ្សព្វផ្សាយពិសេសដើម្បីអភិវឌ្ឍន៍ធនធានមនុស្សដោយភ្ជាប់ជាមួយធានធាន ធម្មជាតិ (ហុង ហឺ-Hong He) ។

មុនពេលផ្តល់ជំនួយដល់កសិករយើងគួរស្តាប់នូវសំណូមពររបស់ពួកគេ ។ ក្របខណ្ឌ និងឧបករណ៍ទាំងនេះនឹងផ្តល់ឱ្យយើង (ពួកគេ) យល់កាន់តែច្បាស់អំពីស្ថានភាពពិតប្រាកដរបស់ពួកគេ ។ វាត្រូវតែចំណាយពេលជាច្រើនដើម្បីប្រើប្រាស់ឧបករណ៍ទាំងនោះដែលជា ការងារ ជាប្រចាំរបស់រដ្ឋាភិបាល (Gejiu) ។

ឧបករណ៍ទាំងនេះអាចជួយឱ្យយើងយល់អំពីស្ថានភាព និងតម្រូវការអត្ថិភាពសំរាប់ការអភិវឌ្ឍន៍ ។ ខ្ញុំមកពី Xishuangbanna ដែលទីនោះសំបូរដោយ ធន ធានវារីជាតិ យើងមិនបានធ្វើការវិភាគប្រពន្ធ័យ៉ាងដូច្នេះទេ តែយើងសង្ឃឹមថាយើងនឹងបញ្ចូលទៅក្នុងការងាររបស់យើង ( Xishuangbanna) ។

កាលពីមុន, វិធីសាស្ត្រអង្កេតរបស់យើងផ្អែកលើ គោលបំណងរបស់ភ្នាក់ងារដែលសំរេចថាតើត្រូវការដឹងអ្វីខ្លះពីសហគន៍ ។ ឧបករណ៍ទាំងនេះផ្តល់ឱ្យយើងនូវឱកាសដើម្បីស្វែងយល់អំពី ស្ថានភាពពិតប្រាកដ ហើយយើសង្ឃឹមថាយើងប្រើប្រាស់ឧបករណ៍ទាំងនេះនិងមានឪកាសជាច្រើនទៀតដើម្បីស្វែងយល់ និងចែករំលែកបទពិសោធន៍ (Diquing) ។

ពីមុន, ខ្ញុំបានធ្វើអង្កេតអំពីរបរចិញ្ចឹមជីវិតខ្លះដែរ តែឥឡូវនេះខ្ញុំដឹងថាអ្វីដែលខ្ញុំបានធ្វើមិនបានស៊ីជំរៅ ហើយគ្មានរបៀបទៀតផង ។ មានបញ្ហាជាច្រើនដែលត្រូវកែលំអ ឧទាហរណ៍ សូចនករ និងប៉ារ៉ាម៉ែត្រ ហើយពត៌មានដែលយើងត្រូវប្រមូលគួរតែពង្រីកបន្ថែមទៀត ។ (Lijian)

ក្នុងប្រទេសចិន យើងគួរប្រើគោលការណ៍របរចិញ្ចឹមជីវិត និងការវិភាគដើម្បីទទួលបានដំណោះស្រាយមួយដ៏ល្អ ។ ដល់បច្ចុប្បន្ននេះ វិស័យជលផលរួមចំណែកដល់វិស័យកសិកម្មចំនួន ៥% ។ កាលពីមុន គោលដៅចំបងរបស់យើងគឺបង្កើនការរួមចំណែកផ្នែកនេះចំពោះប្រាក់ចំណូលរបស់កសិករ ។ ក្រោយពេលសិក្ខាសាលានេះ យើងយល់ឃើញថា ការចិញ្ចឹមជីវិត គឺជាបញ្ហាមួយដ៏ធំ ហើយយើងត្រូវតែក្រឡេកមើលបញ្ហាតាមវិធីផ្សេងៗគ្នា គឺមិនចំពោះតែធ្វើតាមទស្សនៈរបស់វិស័យជលផលប៉ុណ្ណោះទេ ។ គោលការណ៍នេះមានលក្ខណៈជាប្រពន្ធ័ ដែលពីមុនយើងបដិសេធន៍ ។ វិធីសាស្ត្ររបស់យើងត្រូវបានបំបែកជាផ្នែកៗ ហើយធ្វើការដោយឡែកៗពីគ្នា ដែលជាហេតុធ្វើឱ្យយើងមិនអាចទទួលបានលទ្ធផលជាដុំកំភួន (Hong He) ។



ប្រសិនបើយើងប្រើប្រាស់វិធីនេះសំរាប់ធ្វើអង្កេតនោះ វាធ្វើឱ្យយើងភ្នាក់ងាររដ្ឋាភិបាលមានមូលដ្ឋានគ្រឹះក្នុងការធ្វើផែនការ ហើយអាចជួយភ្នាក់ងារទាំងនោះធ្វើរឿងល្អៗសំរាប់សហគមន៏ ។ យើងសង្ឃឹមថាប្រទេសរបស់យើងនឹងជាផ្នែកមួយសំរាប់ជាបណ្តាញពត៌មាន និងចែករំលែកបទពិសោធន៏ ហើយយើងនឹងពិនិត្យមើលនូវលទ្ធភាពសំរាប់ជំនួយផ្សេងៗ ។ (Gejiu)

ខ្ញុំធ្លាប់បានគិតអំពី ការចិញ្ចឹមជីវិតក្នុងផ្លូវមួយដ៏តូចចង្អៀត ឥឡូវការគិតរបស់ខ្ញុំធំទូលាយ និងមានមានលក្ខណៈធំជាងមុន ។ ជាមួយឧបករណ៍ទាំងអស់ ខ្ញុំមានការយល់ដឹងជាមុន ជាពិសេសការយល់ដឹងអំពីស្ថានភាពតាមជនបទ ។ យើងទើបតែរៀនសូត្រប្រៀបដូចជាសិស្សានុសិស្សផ្នែកវិទាសាស្ត្រធម្មជាតិ ប៉ុន្តែដំណោះស្រាយដ៏ល្អទាំងនេះ នឹងរួមបញ្ចូលជាមួយវិទ្យាសាស្ត្រសង្គម ដែលជាការមួយកាន់តែល្អដើម្បីធ្វើការនៅតំបន់ជនបទ ។ ក្នុងពេលអនាគត់ ខ្ញុំនឹងពិនិត្យមើលអំពី ក្របខណ្ឌ័នៃការចិញ្ចឹមជីវិត និងត្រៀមខ្លួនជានិច្ចដើម្បីធ្វើកិច្ចការទាំងអស់នេះ ។ វាជាបទពិសោធន៏មានលក្ខណៈអន្តរជាតិដែលត្រូវប្រើប្រាស់សំរាប់លក្ខណ្ឌ័ ប្រទេសចិន ខ្ញុំនឹងជាផ្នែកមួយនៃបណ្តាញការងារ និងចែករំលែកបទពិសោធន៏ជាមួយអ្នកដ៏ទៃ (Hong He) ។

ទាមរយៈការគោលការណ៍របរចិញ្ចឹមជីវិត និងការវិភាគ យើងមានការយល់ដឹងច្រើនជាងមុន ហើយអាចបង្កើតជាកម្មវិធីដែលអាចជួយដល់ប្រជាជនក្រីក្រតាមជនបទ ។ នេះជាវគ្គបណ្តុះបណ្តាលមួយដ៏ល្អសំរាប់មន្ត្រីជលផលថ្នាក់ខេត្ត ។ វាជាឱកាសដ៏ល្អសំរាប់ពួកយើងដើម្បីជួយសហគមន៏ក្រីក្រឱ្យល្អជាងមុន និងមានប្រសិទ្ធិភាព ។ សិក្ខាសាលានេះធ្វើឱ្យយើងមានអារម្មណ៏ថា យើងមានការទទួលខុសត្រូវក្នុងការជួយប្រជាជនក្រីក្រ ។ យើងបានធ្វើការសិក្សាលទ្ធភាពជាមួយកសិករ និងធ្វើការវាយតំលៃផងដែរ ។ វិធីសាស្ត្រទាំងនេះអាចជួយយើងឱ្យធ្វើការងារបានល្អ និងផ្តល់ឱកាសឱ្យយើងក្នុងការបង្កើទចាត់រោងដោយមានការចូលរួមពីកសិករ ហើយធ្វើឱ្យអ្នកនយោបាយយល់កាន់តែច្បាស់អំពីស្ថានភាពពិតប្រាកដរសប់កសិករ (Kunming) ។

Susan Li មានតួនាទីជា STREAM Communications Hub Manager (Acting) នាយកដ្ឋានកសិកម្មក្នុង Kunming, Yunnan ប្រទេសចិន ។ អាស័យដ្ឋានទំនាក់ទំនង blueseven@mail.china.com

លោក William Savage មានតួនាទីជា Communications Specialist ជាមួយគំរោង STREAM Initiative នៅទីក្រុងបាងកក អាស័យដ្ឋានទំនាក់ទំនង savage@loxinfo.co.th

## ពត៌មានពីទស្សនាវដ្តីរបស់ STREAM


បោះពុម្ពដោយ STREAM- Support to Regional Aquatic Resources Management

Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand

ក្រុមអ្នកបោះពុម្ពផ្សាយ

Kath Copley, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Graham Haylor, នាយកនៃគំរោង STREAM

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM


## គោលបំណង

ទស្សនាវដ្តីរបស់ STREAMបោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម, ទំនាក់ទំនង, និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាងទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់។ ទស្សនាវដ្តីរបស់ STREAMមានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជនដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុងសហគមន៍។ បញ្ហាមានដូចជា: ការរៀនសូត្រ, ការគ្រប់គ្រងជំលោះ, បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន, ការគ្រប់គ្រងធនធានវារិជាត, ច្បាប់, ការចិញ្ចឹមជីវិត, យិនឌ័, ការចូលរួម, អ្នកជាប់ពាក់ពន្ធ័, គោលនយោបាយ និង ទំនាក់ទំនង។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្តី STREAM គឺផ្តល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរ មានដើម្បីឱ្យគេបានលឺ និងមានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ទិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ ។ មាតិកាក្នុងទស្សនាវដ្តីមិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនៈនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ មនុស្សម្នាក់ៗដោយ

ផ្អែកលើបទពិសោធរបស់ពួកគេ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេហើយ STREAM ទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ។

## ការចែកចាយ

ទស្សនាវដ្តីរបស់ STREAM អាចរកបានជា ៣ ទំរង់

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក

ទស្សនាវដ្តីរបស់ STREAMលើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធាន វារីជាតិ និង មនុស្សដែលធ្វើការជាមួយពួកគេ។ ទស្សនាវដ្តីរបស់ STREAMkក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់ សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធរបស់ពួកគេនៅក្នុងទំព័រទាំងនេះ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១០០០ ពាក្យ (ប្រហែល ២ ទំព័រ A4)

អ្នកអាចផ្តល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្តីរបស់ STREAMតាមរយៈ savage@loxinfo.co.th.

ពត៌មានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th

## ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់ )ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈ ពេល៥ឆ្នាំនៃកម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌល វារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។
គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និងស្ថាប័នផ្សេង១ឱ្យៈ

- ប្រើប្រាស់ពតិមានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ និង
- អាចឱ្យប្រជាជន ក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។

គំរោង នឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៍គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និងការកសាងសមត្ថភាពដើម្បីៈ

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានវារីជាតដែលជះឥទ្ធិពលទៅលើជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេង១គ្នា
- ផ្សព្វផ្សាយពតិមាន
- ធ្វើបណ្តាញនៅក្នុង/រវាងវិស័យ និងរវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការករកើតនូវការរួបរួមជាដៃគូរ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាងអ្នកជាប់ពាកលពន្ធ័ទាំងអស់ដែលជាប់ទាក់ទិននិងការគ្រប់គ្រងធនធានវារីជាត និងជួយពួកគេឱ្យរួម ចំណែកក្នុងការរៀបចំ, អនុវត្តន៍ និងការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូរត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយ១តាមរយៈក្រុមសំរបសំរួលជាតិ ដែលរួម មានៈ អ្នកសំរបសំរួលជាតិ ( មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ ទំនង ( ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូងដោយ STREAM)ហើយភ្ជាប់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ផ្សេង១ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware( មានដូចជា កុំព្យូទ័រ ម៉ាស៊ីនស្កេន...), Software ( កម្មវិធីកុំព្យូទ័រ ដូចជា word, excel..), បំពាក់បំប៉ន, ការជួយឧបត្ថម្ភដល់បច្ចេកវិទ្យាពតិមាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ពន្ធ័តាមរយៈ Internet ។

ការសំរបសំរួលជាតិគឺអនុវត្តទៅតាម អត្ថបទយុទ្ធសាស្ត្រនៃប្រទេស(CSP) ដោយមានការពិនិត្យឡើងវិញជារៀង រាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកជាប់ពាក់ពន្ធ័។ CSP រកឱ្យឃើញនូវបញ្ហា, ផ្តោតលើទំនាក់ទំនងក្នុងតំបន់, ធ្វើសំណើរ និង ធ្វើអាទិភាព សកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និងពីកន្លែងផ្សេងៗទៀត (ដោយមាន ការជួយជ្រោមជ្រែងពី STREAM )។

ការិយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក)ដឹកនាំគំរោង, ផ្តល់នូវតួនាទី សំរបសំរួលក្នុងតំបន់, និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹង ការចិញ្ចឹមជីវិត, ការអភិវឌ្ឍន៏គោលនយោ បាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និង វៀតណាមដែលជាកន្លែងមានឳកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និងលើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៏, មេរៀនត្រូវ បានរៀន, ការជះឥទ្ធិពលត្រូវបានដឹង, ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមាន ទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការ បានជា ពត៌មានដល់ ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច។ ទស្សនាវដ្តីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ។

អាស័យដ្ឋានទំនាក់ទំនង:

STREAM National Communications Hub Managers


Cambodia : Sem Viryak, < cfdo@camnet.com.kh >
Philippines : Elizabeth Gonzales < streambfar-phil@skyinet.net >
Nepal : Nilkanth Pokhrel < agroinfo@wlink.com.np >
Vietnam : Nguyen Song Ha < nguyensongha@fpt.vn >
India : Rubu Mukherjee <rubumukherjee@rediffmail.com>
Indonesia : Aniza Suspita <indostream@perikanan-budidaya.go.id>
Lao PDR : Phanthavong Vongsamphanh <phanthavongkv@hotmail.com>
Myanmar : Khin Maung Soe <aquadof@myanmar.com.mm>
Pakistan : Muhammad Junaid Wattoo <junaid_narc@yahoo.com>
Sri Lanka : Athula Senaratne <athulahsenaratne@yahoo.com>
Yunnan, China : Susan Li <blueseven@mail.china.com